“ឯកសារនេះត្រូវបានបកប្រែចេញពីឯកសារស្របច្បាប់ដែល HUD បានចេញផ្សាយ ។ HUD ផ្តល់ការបកប្រែនេះជូនអ្នក គឺគ្រាន់តែជាការផ្តល់ភាពងាយស្រួល ដើម្បីជួយអ្នកឲ្យយល់ដឹងអំពីសិទ្ធិ និង កាតព្វកិច្ចរបស់អ្នកតែប៉ុណ្ណោះ ។ កំណែជាភាសាអង់គ្លេសនៃឯកសារនេះ គឺជាឯកសារផ្លូវការ ពេញច្បាប់ និង ជាឯកសារបានត្រួតពិនិត្យ ។ ឯកសារដែលបានបកប្រែនេះ គឺមិនមែនជាឯកសារផ្លូវការឡើយ ។

**អំពើហឹង្សាអំពើហឹង្សាពេល ណាត់ជួប ឬការរំខានយាយី**

**ក្រសួងទីលំនៅ និងអភិវឌ្ឍន៍ទីក្រុងនៃសហរដ្ឋអាមេរិក**
**ការិយាល័យទីលំនៅ**

OMB យល់ព្រមលេខ 2502-0204
ផុតកំណត់ 05/31/2011

# ឧបសម្ពន្ធនៃកិច្ចសន្យាជួល

## ច្បាប់អំពើហឹង្សាលើស្ត្រី និងវិសោធនកម្មរបស់ក្រសួងយុត្តិធម៌ឆ្នាំ 2005

| អ្នកជួលលំនៅ | ម្ចាស់លំនៅ | លំនៅលេខ និង អាសយដ្ឋាន |
|---|---|---|
| | | |

ឧបសម្ពន្ធនៃកិច្ចសន្យាជួលនេះបន្ថែមលើកថាខណ្ឌខាងក្រោមចំពោះកិច្ចសន្យាជួលរវាងអ្នកជួលលំនៅ និងម្ចាស់លំនៅដែលបានយោងខាងលើ។

### គោលបំណងនៃឧបសម្ពន្ធ

កិច្ចសន្យាជួលលំនៅដែលបានយោងខាងលើត្រូវបានកែដើម្បីរាប់បញ្ចូលនូវបទបញ្ញត្តិនៃច្បាប់អំពើហឹង្សាលើស្ត្រី និង វិសោធនកម្មរបស់ក្រសួងយុត្តិធម៌ឆ្នាំ 2005 (Violence Against Women and Justice Department Reauthorization Act of 2005, VAWA)។

### វិវាទជាមួយបទបញ្ញត្តិដទៃនៃកិច្ចសន្យាជួល

ក្នុងករណីមានវិវាទរវាងបទបញ្ញត្តិនៃឧបសម្ពន្ធនេះ និងប្រការដទៃនៃកិច្ចសន្យាជួលនេះ បទបញ្ញត្តិនៃឧបសម្ពន្ធនេះត្រូវមានអាទិភាព។

### លក្ខខណ្ឌនៃឧបសម្ពន្ធនៃកិច្ចសន្យាជួល

សុពលភាពនៃកាលបរិច្ឆេទរបស់ឧបសម្ពន្ធនៃកិច្ចសន្យាជួលនេះគឺ _____________។
ឧបសម្ពន្ធនៃកិច្ចសន្យាជួលនេះត្រូវបន្តសពុលភាពរហូតដល់កិច្ចសន្យាជួលត្រូវបានបញ្ចប់។

### ការការពាររបស់ VAWA

1. ម្ចាស់លំនៅអាចមិនបានចាត់ទុកឧប្បត្តិហេតុនៃអំពើហឹង្សាក្នុងគ្រួសារ អំពើហឹង្សាពេលណាត់ជួប ឬការរំខានយាយី ថាជាការបំពានធ្ងន់ធ្ងរ ឬដដែលៗនៃកិច្ចសន្យាជួល ឬក៏ “បុព្វហេតុល្អ” ដទៃសម្រាប់ការបញ្ចប់សិទ្ធិទទួលជំនួយ ទីលំនៅ ឬ កន្លែងស្នាក់នៅរបស់ជនរងគ្រោះនៃការបំពានឡើយ។
2. ម្ចាស់លំនៅអាចមិនបានចាត់ទុកសកម្មភាពព្រហ្មទណ្ឌដោយផ្ទាល់ទាក់ទងនឹងការបំពាន ដែលជាប់ពាក់ព័ន្ធដោយសមាជិកម្នាក់នៃគ្រួសាររបស់អ្នកជួលលំនៅ ឬភ្ញៀវណាម្នាក់ ឬបុគ្គលដទៃ ក្រោមការគ្រប់គ្រងរបស់អ្នកជួលលំនៅ ថាជាបុព្វហេតុសម្រាប់ការបញ្ចប់សិទ្ធិទទួលជំនួយ ទីលំនៅ ឬកន្លែងស្នាក់នៅ ប្រសិនបើអ្នកជួលលំនៅ ឬសមាជិកផ្ទាល់នៃគ្រួសាររបស់អ្នកជួលលំនៅគឺជាជនរងគ្រោះ ឬជនរងគ្រោះដែលទទួលការគម្រាមកំហែងនៃការបំពាននោះ។
3. ម្ចាស់លំនៅអាចស្នើជាលាយលក្ខណ៍អក្សរឲ្យជនរងគ្រោះ ឬសមាជិកគ្រួសារក្នុងនាមជនរងគ្រោះ បញ្ជាក់ថាបុគ្គលនោះគឺជា ជនរងគ្រោះនៃការបំពាន និងដែលថាសេចក្តីបញ្ជាក់អំពីអំពើហឹង្សាក្នុងគ្រួសារ អំពើហឹង្សាពេលណាត់ជួប ឬការរំខានយាយី (Certification of Domestic Violence, Dating Violence or Stalking ), ទម្រង់ HUD-91066 ឬ ឯកសារដទៃដូចបានកត់សម្គាល់លើទម្រង់សេចក្តីបញ្ជាក់ ត្រូវបានបំពេញ និង ប្រគល់ ក្នុងរយៈពេល 14 ថ្ងៃធ្វើការ ឬ កាលបរិច្ឆេទពន្យារដែលបានយល់ព្រមដើម្បីទទួលការការពារក្រោម VAWA។ ការខកខានផ្តល់សេចក្តីបញ្ជាក់ ឬ ឯកសារគាំទ្រដទៃក្នុងអំឡុងពេលដែលបានបញ្ជាក់អាចនាំឲ្យមានការបណ្តេញចេញ។

| បានលុបបន្ទាត់ហត្ថលេខា |
|---|